ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ.១៣៩....../ រ.ប.ក

# របាយការណ៍ត្រីមាសទី២
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅត្រីមាសទី៣ ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ-១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ-១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌៖ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ខ.១.១. ការផ្សព្វផ្សាយដោយផ្ទាល់

| បរិយាយ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ | ១៧.៦៣៨ | ១.៣០៧.០៧៨ | ៧១៨.០១០ |
| ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ | ០៣ | ១.០៨៦ | ៤៥៤ |
| សរុប | ១៧.៦៤១ លើក | ១.៣០៨.១៦៤ នាក់ | ៧១៨.៤៦៤ នាក់ |

ខ.១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **១៧.៦៣៨**លើក មានអ្នកចូលរួមសរុបចំនួន **១.៣០៧.០៧៨**នាក់ (បើធៀបនឹងត្រីមាសទី២ ឆ្នាំ២០២១ មានចំនួន **៩០៧.២៣៩**នាក់ គឺមានការកើនឡើងចំនួន **៣៩៩.៨៣៩**នាក់ ស្មើនឹង៤៤%) ក្នុងនោះស្ត្រីចំនួន **៧១៨.០១០**នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៤០ | ១៨.៤០៣ | ៩.៩២៩ | ២០៧ | ១០.៦៧១ | ៥.៥១៣ |
| | សរុប ក្រសួង ស្ថាប័ន | ១៤០ លើក | ១៨.៤០៣ នាក់ | ៩.៩២៩ នាក់ | ២០៧ លើក | ១០.៦៧១ នាក់ | ៥.៥១៣ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ២.៣៩៤ | ៨៩.៧២០ | ៥២.៤៦៦ | ២.៦៤៦ | ១២៥.២៨៩ | ៦៤.៨២៤ |
| ៣ | ខេត្តបាត់ដំបង | ៣.០៥១ | ១៣៣.១៨៥ | ៧១.២៥៥ | ២.១៤៨ | ៧៤.៧៨៦ | ៤០.០៣៧ |
| ៤ | ខេត្តពោធិ៍សាត់ | ១.៣៩០ | ១៣១.០២៣ | ៧២.១៧៩ | ៣៥៤ | ១៣.២១៤ | ៦.០៦៩ |
| ៥ | ខេត្តសៀមរាប | ១៧៦ | ៨.៩២៩ | ៥.៤៣៦ | ៧០ | ៣.៤៥៥ | ១.៩១៦ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣.០៨៨ | ៨១.៤៤៥ | ៤២.០៤៣ | ១.៦៨៧ | ៣០.៥៣២ | ១៥.២៧៩ |
| ៧ | ខេត្តកំពង់ចាម | ៥.៤០៤ | ១៩០.៦០៣ | ១៥៥.៣៦២ | ៣.២៩៤ | ៩៦.៩៥៥ | ៥៣.៦៥៥ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ១៤ | ១.៩៥៨ | ១.០៧៨ | | | |
| ១០ | ខេត្តស្វាយរៀង | ៤ | ៩៨៩ | ៣៣៨ | ៨២៣ | ២៧.៤២៩ | ១៥.២៤០ |
| ១១ | ខេត្តប៉ៃលិន | ២៣០ | ៣.៧៩២ | ៦៨៦ | ១០៦ | ៣.៧៥៩ | ៦៨១ |
| ១២ | ខេត្តកោះកុង | ៤៧ | ១.១៩២ | ៦៧៦ | ៤៤ | ៧៦៧ | ៣៣១ |
| ១៣ | ខេត្តកំពត | ១ | ២០០ | ១៩០ | | | |
| ១៤ | ខេត្តកំពង់ធំ | ៣៩ | ២.៧៥១ | ១.៩៥២ | | | |
| ១៥ | ខេត្តតាកែវ | ៩៦៨ | ២៥.៦៨៤ | ១១.៤៦៨ | ២៨៧ | ១៦.២០៥ | ៧.៨៤៩ |
| ១៦ | ខេត្តក្រចេះ | ៦៧ | ៣.៧៩៣ | ១.៨៥៤ | | | |
| ១៧ | ខេត្តកែប | ៧៩ | ១៣.០៨៣ | ៥.៤០៧ | ១២៩ | ៥.២១២ | ២.៦៨២ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ១ | ៩១ | ៦៣ | ១ | ១៣៣ | ៩៩ |
| ២០ | ខេត្តរតនគិរី | ៤២ | ១.៩០៥ | ១.០៧៥ | | | |
| ២១ | ខេត្តព្រៃវែង | ៣១៧ | ១៨.២៧៩ | ៨.៩៤១ | ៣១៦ | ១៨.០៧៩ | ៨.៨២៦ |
| ២២ | ខេត្តត្បូងឃ្មុំ | ២ | ២.៧៣៤ | ១.៤៣២ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១០ | ១០៨ | ៨៤ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣ | ១.៨៥០ | ១.៣១៥ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ១៧១ | ៣.០២៣ | ១.១១១ | | | |
| | សរុប រាជធានី-ខេត្ត | ១៧.៤៩៨លើក | ៧១៦.៣៣៧នាក់ | ៤៨៥.០៨០នាក់ | ១១.៩០៥លើក | ៥៦១.៦៦៧នាក់ | ២១៧.៤៨៨នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ១៧.៦៣៨ លើក | | ចំនួនមនុស្សសរុប ១.៣០៧.០៧៨ នាក់ | | ចំនួនស្ត្រី ៧១៨.០១០ នាក់ | |

### ខ.១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបើកពិធីផ្សព្វផ្សាយរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងទិសដៅអនុវត្តឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ អ្នកចូលរួមសរុបប្រមាណ ៣៥០នាក់ នៅវិទ្យាស្ថានជាតិអប់រំ។

- **ខេត្តសៀមរាប៖** មន្ទីរអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ APLE រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពី ការស្វែងយល់អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ចំនួន ០២លើក មានអ្នកចូលរួម ៧៣៦នាក់ ស្រី៤៥៤នាក់។

**ខ.១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - បានសហការជាមួយ **និយ័តករកម្ពុជា** (TRC) ធ្វើការផ្ញើសារអប់រំតាមរយៈទូរស័ព្ទចល័ត នៅថ្ងៃទិវាកុមារអន្តរជាតិ ០១មិថុនា ដែលមានខ្លឹមសារ "រួមគ្នាលុបបំបាត់រាល់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ"។
  - បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈផេកហ្វេកប៊ុក មានអ្នកចូលមើល១.៤៣០នាក់។
- **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ១៥០លើក ក្នុងមួយថ្ងៃ ១៥លើក។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំនៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្តស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងវិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ចំនួន១៧០លើក(ផ្សាយផ្ទាល់ ៥២លើកនិងចាក់ផ្សាយឡើងវិញ១១៨លើក)។
- **ខេត្តបាត់ដំបង៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបចំដោយអង្គការប្រតិបត្តិការកុមារកម្ពុជា នៅស្រុកថ្មគោល ០១លើក មានអ្នកចូលរួម៣០នាក់ ស្រី១៦នាក់។
- **ខេត្តកំពង់ចាម៖** មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិភ្នំស្រីភ្នំប្រុស ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន ៩០លើក។

**ខ.១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជាប្រធានប្រតិភូកម្ពុជា របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ (អ.ស.ប) បានអញ្ជើញចូលរួមជាគណៈអធិបតី និងជាវាគ្មិននៅក្នុងវេទិកាពិភាក្សា លើការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារនៅកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ។
  - លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ LOVE FM ដើម្បីឆ្លើយតបសំណួរ ពាក់ព័ន្ធនឹងស្ថានភាពរបស់ពលករចំណាកស្រុក ក្រោយពេលជំងឺកូវីដ-១៩ បានធូរស្រាល។
  - លោកឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង និងលោកឧត្តមសេនីយ៍ទោ **វ៉ន សុភ័ក្រ្តវឌ្ឍនា** ប្រធានក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ បានអញ្ជើញជាគ្រូបង្គោលធ្វើបទឧទ្ទេសច្បាប់ដល់សិក្ខាកាមជាកងកម្លាំងគ្រាប់មិនទាន់ផ្ទុះ ដែលត្រៀមចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពរបស់ អ.ស.ប នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ចំនួន ៤៥នាក់(ស្រី ០៥នាក់) នៅសាលាហ្វឹកហ្វឺនបណ្តុះបណ្តាល កងកម្លាំងរក្សាសន្តិភាពពហុជាតិ។

- ខេត្តបាត់ដំបង៖
  - បានចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីសន្ទនាមតិ ស្តីពី "ទប់ស្កាត់ការជួញដូរមនុស្សឆ្លងដែនខុសច្បាប់" របស់វិទ្យុជាតិកម្ពុជាខេត្តបាត់ដំបង។
  - បានចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាសាធារណៈស្តីពីហិង្សាយេនឌ័រ អំពើជួញដូរមនុស្ស និងសុវត្ថិភាពទេសន្តរប្រវេសន៍ នៅទីធ្លាវត្តអូរជុំឧត្តមសាមគ្គី ភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។
- ខេត្តកំពង់ចាម៖
  - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិននៅវិទ្យុជាតិខេត្ត ស្តីពី ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់ក្រោយពីពីបុណ្យចូលឆ្នាំថ្មី និងការផ្សព្វផ្សាយពីនីតិវិធីនៃការរៀបការជាមួយជនបរទេស ០៣លើក។
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនក្នុងវិទ្យុ ក្រោមប្រធានបទ «ការទប់ស្កាត់ការចំណាកស្រុកខុសច្បាប់ ក្រោយពិធីបុណ្យចូលឆ្នាំថ្មី»។

**ខ.១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- ខេត្តបន្ទាយមានជ័យ៖
  - អង្គការសាម៉ារីតាន់ភឺស ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាក ស្រុកដោយសុវត្ថិភាពចំនួន ១៣.០៨៣នាក់ (ស្រី ៥.៤២៤នាក់) អនីតិជន១.៤២៧នាក់។
  - អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ចែកសៀវភៅការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ២.៦៧៤នាក់ (ស្រី ១.១៧៤នាក់)។
- ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន ២៣៤នាក់ (ស្ត្រី ១០៧នាក់) កុមារ ២៦នាក់។

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

**ខ.២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១០៦.៦០១នាក់(ស្រី ៤៦.៥១៧នាក់) អនីតិជន៩៤២នាក់(ស្រី៣២៣នាក់)៖
  - ចេញទៅដោយស្របច្បាប់ចំនួន ៨២.១៧៧នាក់(ស្រី៣៦.៥៣៥នាក់) អនីតិជន១៧០នាក់ (ស្រី ៦៤នាក់)។
  - ចេញទៅដោយមិនស្របច្បាប់ចំនួន ២៣.៨៦១នាក់(ស្រី៩.៧១៦នាក់) អនីតិជន ៦៦៨៩នាក់ (ស្រី២៣០នាក់)។
  - ដាច់ការទាក់ទងចំនួនន ៥៦៣នាក់(ស្រី២៦៦នាក់) អនីតិជន១០៤នាក់(ស្រី២៩នាក់)។
- កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្ត**បន្ទាយមានជ័យ និងខេត្តបាត់ដំបង** បានធ្វើការបង្ការទប់ស្កាត់ ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ចំនួន ២៩លើក មនុស្ស ៤៦៨នាក់ ស្រី១៩៧នាក់ អនីតិជន៤៧នាក់ បានសាកសួរព័ត៌មានដើម្បីស្វែងរកមេខ្យល់ និងធ្វើកិច្ចសន្យាអប់រំរួចបញ្ជូនទៅលំនៅដ្ឋានវិញ។

**ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ តាកែវ កំពង់ចាម កែប សៀមរាប និងខេត្តកោះកុង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្មដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ជាប្រចាំក្នុងនោះ៖

- ខែមេសា ចំនួន ២៣៩គោលដៅ មនុស្សចំនួន ៦៧៦នាក់(ស្រី៥៣២នាក់)
- ខែឧសភា ចំនួន ១៩៤គោលដៅ មនុស្សចំនួន ៥១៧នាក់(ស្រី៣៩០នាក់)
- ខែមិថុនា ចំនួន ១៨៥គោលដៅ មនុស្សចំនួន ៤៩៤នាក់(ស្រី៣៣៤នាក់)។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន៖

*តារាងការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ឆ្នាំ២០២២*

| ស្នងការដ្ឋាននគរបាល រាជធានី ខេត្ត | ខែមេសា | ខែឧសភា | ខែមិថុនា |
|---|---|---|---|
| | ០៣ លើក | ០៧ លើក | ០៧ លើក |
| សរុប | ១៧ លើក | | |

**ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ចំនួន ៣៤៩នាក់ និងវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយ ចំនួន ៣២០នាក់។ ព្រមទាំងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមទូរស័ព្ទចំនួន២៣នាក់(ស្រី១៣នាក់)មានសេចក្តីសុខធម្មតា។

## ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះទៅណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រ សហគ្រាស កន្លែងលាងឡាន និងកន្លែងកម្សាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដានការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុក្រោម៣ឆ្នាំ និងបានផ្សព្វផ្សាយដល់សិស្សដែលរៀនថ្នាក់អក្ខរកម្មវិជ្ជាជីវៈ ថ្នាក់សមមូលបឋមសិក្សា និងថ្នាក់មជ្ឈមណ្ឌលសិក្សា សហគមន៍ តាមភូមិ ឃុំ និងក្រុង ស្រុក ដែលបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ។
- **ខេត្តក្រចេះ៖**
  - មន្ទីរអប់រំ យុវជន និងកីឡា បានចុះផ្សព្វផ្សាយពីរបៀបធ្វើទិវាទប់ស្កាត់ការជួញដូរមនុស្ស នៅបឋមសិក្សាថ្មហាលវាល និងបឋមសិក្សាផ្សារស្នួល ស្រុកស្នួល ដែលមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ចូលរួមសរុប៦៩៩នាក់ ស្រី៣៤២នាក់។
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារនៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ០៣លើកជាលទ្ធផលឃើញថាការថែទាំ និងការឧបត្ថម្ភដល់កុមារមានដំណើរការល្អប្រសើរ។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

**គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៣៧ករណី(បើធៀបនឹង

ត្រីមាសទី២ ឆ្នាំ២០២១ មានចំនួន **១១៤**ករណី ថយចុះ**៧៧**ករណី) ស្មើនឹង**៦៧,៥៤%** ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន៤០នាក់(អនីតិជន០៥នាក់ ជនបរទេស០៥នាក់(ចិន០៤នាក់ វៀតណាម០១នាក់))។

សង្គ្រោះជនរងគ្រោះចំនួន **៧០**នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ **២៩**នាក់ អាយុ១៥-១៧ឆ្នាំ **០៤**នាក់ និង អាយុពី១៨ឆ្នាំឡើង **៣៧**នាក់ (ប្រគល់ឱ្យគ្រួសារ **៦៩**នាក់ និងមន្ទីរសង្គមកិច្ច **០១**នាក់) ក្នុងនោះចែកជា៖

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **០៥**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **០៥**នាក់(ចិន០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន **២១**នាក់ អាយុក្រោម១៥ឆ្នាំ **០១**នាក់ អាយុ១៥-១៧ឆ្នាំ **០៣**នាក់ អាយុ១៨ឆ្នាំឡើង **១៧**នាក់ (ប្រគល់ឱ្យគ្រួសារ **២១**នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន | ០៣ | ១៥ | ០៣ | |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០៥ | ០១ | |
| -អំពើលក់ដូរមនុស្ស | ០១ | ០១ | ០១ | ចិន ០១ |
| *សរុប* | *០៥ ករណី* | *២១ នាក់* | *០៥ នាក់* | *០១នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន **៣២**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **៣៥**នាក់(ស្រី០២នាក់) ជនសង្ស័យជាអនីតិជន ០៥នាក់ និងបរទេស០៤នាក់។ សង្គ្រោះជនរងគ្រោះចំនួន **៤៩**នាក់ អាយុក្រោម១៥ឆ្នាំ **២៨**នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង **២០**នាក់ (ប្រគល់ឱ្យគ្រួសារ **៤៨**នាក់ និងមន្ទីរសង្គមកិច្ច **០១**នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម | ០១ | ១៨ | ០២ | ចិន០២ |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០១ | ០១ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ០២ | ០២ | ០២ | ចិន០១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៨ | ១៨ | ២០ (អនី.០៣) | វៀតណាម០១ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៩ | ០៩ | ០៩ | |
| *សរុប* | *៣២ ករណី* | *៤៩នាក់* | *៣៥ នាក់ (អនី.០៣នាក់)* | *០៤ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

**ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

សហការជាមួយមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត និងអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុប៤៦នាក់(ស្ត្រី៣៧នាក់ កុមារី០១នាក់) មកពីប្រទេសចិន ៣៧នាក់ និងម៉ាឡេស៊ី ០៩នាក់ ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ៤០នាក់ និងងាយរងគ្រោះ០៦នាក់ បានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសម្ភាសន៍ជនរងគ្រោះ បញ្ជូនមកពីក្រៅប្រទេស ចំនួន៤៥នាក់(ស្រី៣០នាក់) អនីតិជន០៤នាក់ មកពីប្រទេសចិន ៣៧នាក់(ស្រី) (អនីតិជន០៤នាក់) និងប្រទេសម៉ាឡេស៊ី ០៨នាក់(ស្រី០២នាក់)។ ជាលទ្ធផលរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ធៈទៅចិន ៣០នាក់(អនីតិជន០៤នាក់) និងរងគ្រោះដោយស្នាក់នៅខុសច្បាប់នៅចិន ០៧នាក់(ស្រី០៣នាក់) និងនៅម៉ាឡេស៊ី ០៨នាក់(ស្រី០២នាក់)។
  - **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារបានទទួល នឹងសម្ភាសន៍ជនទេសន្តរប្រវេសន៍(ពលរដ្ឋខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចំនួន **៣៤២**លើក មនុស្សចំនួន **២៧.៩១៧**នាក់ (ស្ត្រី ៩.៦៧៤នាក់) អនីតិជន ៣.៤០៥នាក់។
  - **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៤៣លើក មនុស្សចំនួន ៨៩៤នាក់ ស្រី២២៨នាក់ អនីតិជន១២០នាក់។
  - **ខេត្តប៉ៃលិន** បានទទួលពលរដ្ឋខ្មែរ ដែលត្រឡប់ពីប្រទេសថៃតាមច្រកព្រំដែន និងច្រកអន្តរជាតិ ចំនួន ១៧លើក មនុស្សចំនួន ៣.៧០៨នាក់(ស្រី១.៤៣០នាក់) អនីតិជន ៤៥៥នាក់។
  - **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ០២លើក មនុស្សចំនួន ០៧នាក់(ស្រី០២នាក់) អនីតិជន ០៣នាក់។

**ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ៥៦៦នាក់(ស្ត្រី ០៤នាក់) កុមារ ៥៦២នាក់ (កុមារី ២៦៩នាក់)ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ៥៤នាក់ ជួញដូរផ្លូវភេទ ០៥នាក់ រំលោភបំពានផ្លូវភេទ ៩៣នាក់ និងងាយរងគ្រោះ ៤១៤នាក់ នៅអង្គការ World Mabilization ១៦នាក់ អង្គការបេសកកម្មទូទាំងពិភពលោក ៣៩២នាក់ អង្គការវេណាសេរដើរជាមួយស្ត្រី-កម្ពុជា ០៣នាក់ អង្គការមូលនិធិA21 ៥៣នាក់ អង្គការតេនៈអ៊ីនធឺណេសិនណល ០១នាក់ អង្គការសកម្មភាពដើម្បីកុមារ ៧១នាក់ អង្គការពន្លកថ្មី ៣០នាក់។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍វិញសរុបចំនួន ០៣នាក់(ស្ត្រី) ជាករណីជួញដូរផ្លូវភេទ ដោយបានការចូលរួមសហការគាំទ្រពីអង្គការសង់គ្រាល់ ០១នាក់ និងអង្គការក្តីសង្ឃឹមនិងយុត្តិធម៌ ០២នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| ខេត្តស្វាយរៀង៖<br>- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និងអង្គការហោភារ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ក្រុមការងារថ្នាក់ស្រុក និងឃុំទាំង១៦ ក្នុងស្រុកស្វាយជ្រុំ។ | ០១ | ៤៥ | ២០ |

| | | | |
|---|---|---|---|
| - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនចំនួន១២ បានបើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ។ | ១៣ | ២៤២ | ១៥៧ |
| **ខេត្តតាកែវ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និងអង្គការហាការ បើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០២ស្រុក ស្រុកគិរីវង់ និងស្រុកទ្រាំង។ | ០២ | ២៧ | ១៥ |
| **ខេត្តបាត់ដំបង៖** ស្នងការនគរបាលខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ ឧបត្ថម្ភដោយអង្គការA21 សិក្ខាកាមជាមន្ត្រី មកពីការិយាល័យជំនាញ និងមន្ត្រីនគរបាលស្រុក ក្រុង និងមន្ត្រីសង្គមកិច្ច។ | ០១ | ៣២ | ០៣ |
| **ខេត្តសៀមរាប៖** | | | |
| - លេខាធិការដ្ឋានសហការជាមួយអង្គការជីវិតនៅកម្ពុជា(TLC) និងគាំទ្របច្ចេកទេសពីស្ថាប័នអយ្យការ និងស្នងការដ្ឋាននគរបាលខេត្ត បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី វិធានការបង្វែរអនីតិជនជំទាស់នឹងច្បាប់ ដល់អភិបាលរងស្រុកទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីសង្គមកិច្ចនិងសុខុមាលសង្គម នៅក្នុងក្រុងសៀមរាប ស្រុកពួក ស្រុកក្រឡាញ់ ស្រុកស្រីស្នំ ស្រុកអង្គរជុំ និងស្រុកអង្គរធំ។ | ០២ | ៨៧ | ១០ |
| - ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការ APLE បើកវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់និងឆ្លើយតបបែបកុមារមេត្រីទៅនឹងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ដល់មន្ត្រីពាក់ព័ន្ធនៅស្រុកស្រីស្នំ និងស្រុកអង្គរធំ។ | ០២ | ៧៥ | ១១ |
| - និងសហការជាមួយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) បើកវគ្គបណ្តុះបណ្តាល ស្តីពីវិធានការបង្វែរអនីតិជន ទំនាស់នឹងច្បាប់។ | ០១ | ៤៥ | ០៨ |
| **ខេត្តត្បូងឃ្មុំ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការមូលនិធិហាការអន្តរជាតិ បើកវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងប្រឆាំងអំពើជួញដូរមនុស្ស ជូនដល់រដ្ឋបាលស្រុកក្រូចឆ្មារ និងស្រុកអូររាំងឪ។ | ០១ | ៧១ | ២៤ |
| **ខេត្តកំពង់ឆ្នាំង៖** មន្ទីរកិច្ចការនារី សហការជាមួយ គម្រោងកិច្ចគាំពារសង្គមដើម្បីបញ្ចប់ភាពក្រីក្រ ចុះបើកវគ្គបណ្តុះបណ្តាល ស្តីពីយេនឌ័រ អំពើហិង្សា អំពើជួញដូរមនុស្ស ចំណាកស្រុក និងការបម្រែបម្រួល អាកាសធាតុដល់មន្ត្រី និងប្រជាពលរដ្ឋនៅក្រុងកំពង់ឆ្នាំង និងស្រុកទឹកផុស។ | ០៣ | ១០៩ | ៦៩ |
| **ខេត្តកំពង់ចាម៖** ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការ IJM បើកវគ្គបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់ការជួញដូរមនុស្ស និងទម្រង់នៃការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ។ | ០១ | ៦០ | ១១ |
| សរុប | ២៨ វគ្គ | **៧៩៣** នាក់ | ៣៣៨ នាក់ |

**ក.២. សិក្ខាសាលា**

- **ខេត្តព្រៃវែង៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា សហការជាមួយអង្គការហាការបើកសិក្ខាសាលាស្តីពី ចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស នៅស្រុកកំពង់ត្របែក និងស្រុកព្រះស្តេច មានអ្នកចូលរួម ៦០នាក់។

- **ខេត្តតាកែវ៖** មន្ទីរទេសចរណ៍ខេត្ត បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ ជូនដល់អាជីវករ សេវាករទេសចរណ៍ នៅក្នុងក្រុងដូនកែវ ចំនួន ០១លើក អ្នកចូលរួមចំនួន ៤៥នាក់(ស្រី ១៨នាក់)។
- អង្គការ PLAN International, Cambodia ACTs **និងអង្គការបន្ទាយស្រី** សហការជាមួយលេខាធិការដ្ឋានគ.ខ.ប.ជ ខេត្តសៀមរាប បានរៀបចំសិក្ខាសាលា ស្តីពី **"បិទបញ្ចប់ដំណើរការគម្រោង បញ្ឈប់ការកេងប្រវ័ញ្ចលើកុមារ តាមរយៈការទទួលបានសេវាសមស្រប»** សិក្ខាកាមចូលរួមសរុបចំនួន ៥៧នាក់ (ស្រី ៣៦នាក់)នៅសណ្ឋាគារប៉ាវ៉ាដាយ ខេត្តសៀមរាប។

# ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

## ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

### ខ.១.១. កិច្ចប្រជុំក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)៖**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ៖
  - បើកកិច្ចប្រជុំ ពិគ្រោះយោបល់ជាមួយក្រុមការងារ ក្រសួង ស្ថាប័នជំនាញ យុត្តិធម៌ និងអ្នកអនុវត្តច្បាប់ ស្តីពីករណីពពោះជំនួស ដោយមានការអញ្ជើញចូលរួមពី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការ គ.ជ.ប.ជ ប្រធានសាលាដំបូងរាជធានីភ្នំពេញ ព្រះរាជអាជ្ញារងអមសាលាដំបូង រដ្ឋបាលហិរញ្ញវត្ថុ អនុវត្តច្បាប់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅសាលប្រជុំ គ.ជ.ប.ជ។
  - ចូលរួមក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយបណ្តាញទេសន្តរប្រវេសន៍ នៃអង្គការសហប្រជាជាតិដឹកនាំ និងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ប្រទេសជ័យលាភី GCM អំពី **«ការគ្រប់គ្រងព្រំដែន និងទេសន្តរប្រវេសន៍ការងារ នៅក្នុងបរិបទនៃការស្តារឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩»** ។
  - ដឹកនាំកិច្ចប្រជុំសម្របសម្រួលស្ថាប័នពាក់ព័ន្ធគម្រោង **«សុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា»** នៅមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង។
  - ដឹកកិច្ចប្រជុំពិភាក្សាបន្តលើការងារ SOP បានជួយឧបត្ថម្ភដោយអង្គការ South Asia, IOM, Asean-Act, សហគមន៍អឺរ៉ុប នៅសាលប្រជុំ គ.ជ.ប.ជ។
  - ដឹកនាកិច្ចប្រជុំពិភាក្សាលើផែនការបន្ត លើការប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា ជាមួយប្រធានបេសកកម្មរបស់អង្គការវីនរ៉ក់អន្តរជាតិ នៅសាលប្រជុំ គ.ជ.ប.ជ។
  - ដឹកនាំកិច្ចប្រជុំបច្ចេកទេសបន្តលើខ្លឹមសារ SOP ដោយមានកិច្ចសហការជួយឧបត្ថម្ភគាំទ្រពីអង្គការ IOM, ASEAN-ACT, ESAT- ASEAN, FUNDED BY UNION COMMUNITY មានសមាសភាពចូលចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ និងឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ ក្រសួងការបរទេស ក្រសួងសង្គមកិច្ច ក្រសួងការងារ ក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ និងលោក Khy Lorn ជាមន្ត្រីនៅស្ថានទូតកម្ពុជាប្រចាំនៅទីក្រុងបាងកកជាអ្នកសម្របសម្រួល សរុបចំនួន ៣១នាក់។
  - ដឹកនាំកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំកម្មវិធីអន្តរសាសនា ឆ្នាំ២០២២ ចំនួន ០២លើក ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រោមកិច្ចសហការរវាងគ.ជ.ប.ជ តំណាងសាសនាទាំងបួននៅកម្ពុជា សហការជាមួយអង្គការការីតាសកម្ពុជា មានអ្នកចូលរួមសរុបចំនួន ៤៧នាក់។

○ ដឹកនាំកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ជាមួយអង្គការ RATANAK International ស្តីពី "**កិច្ចសហការ សម្រាប់ការអនុវត្តគម្រោងបង្ការ ទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស**" ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការទាំង៦ និងតំណាងអង្គការ RATANAK International សរុបចំនួន ២០នាក់។

**ខ.១.២. កិច្ចប្រជុំក្រៅប្រទេស**

• **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)៖**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាជាតិដើម្បីកុមារ បានដឹកនាំគណៈប្រតិភូកម្ពុជាមាន០៦រូប ចូលរួមក្នុងកិច្ចប្រជុំ ការពាររបាយការណ៍ថ្នាក់ជាតិលើកទី៤ ទី៥ និងទី៦ ស្តីពី ការអនុវត្តអនុសញ្ញាសិទ្ធិកុមារក្នុងកិច្ចប្រជុំលើកទី៩០ របស់គណៈកម្មាធិការសិទ្ធិកុមារ (CRC) អង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ ។
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច តំណាងពីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីចូលរួម ក្នុងវេទិកាអន្តរជាតិពិនិត្យឡើងវិញនូវការអនុវត្ត GCM ក្នុងនាមកម្ពុជាជាប្រទេស Champion Country នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ជាមួយអង្គការ RATANAK International ស្តីពី "កិច្ចសហការសម្រាប់ការអនុវត្តគម្រោងបង្ការទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស" ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តមលោកជំទាវ អគ្គលេខាធិការរង និងប្រធានក្រុមជំនួយកិច្ចការទាំង៦ និងតំណាងអង្គការ សរុបចំនួន ២០នាក់។

## ខ.២. ជំនួបពិភាក្សាការងារ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖
  **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ៖** បានជួបពិភាក្សាការងារ ជាមួយតំណាងអង្គការសេរីភាពកម្ពុជាអូស្ត្រាលី អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការប្រតិបត្តិយុត្តិធម៌កម្ពុជា ដើម្បីស្វែងយល់បន្ថែមអំពីលទ្ធភាពបង្កើនកិច្ចសហប្រតិបត្តិការជាមួយ គ.ជ.ប.ជ និងទទួលជួបពិភាក្សាការងារ ជាអង្គការវីនរ៉ក់អន្តរជាតិ ប្រគល់-ទទួល សៀវភៅរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ផែនយុទ្ធសាស្ត្រជាតិ៥ឆ្នាំ ២០១៩-២០២៣ នៅសាលប្រជុំ គ.ជ.ប.ជ។
- **ខេត្តកោះកុង៖** លោកស្រី **អ៊ុន សុគន្ធីតា** នាយករងរដ្ឋបាល និងជាអនុប្រធានលេខាធិការដ្ឋាន បានជួបពីភាក្សាជាមួយអង្គការវីនរ៉ក់អន្តរជាតិស្តីពី ការកំណត់ស្រុកគោលដៅដើម្បីអនុវត្តគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងខេត្តកោះកុង ០១លើក។
- **ខេត្តត្បូងឃ្មុំ៖** លោកជំទាវ **នី ចាន់ធីតា** ប្រធានលេខាធិការដ្ឋាន បានដឹកនាំក្រុមការងារជំនាញទាំង០៦ សមាជិកលេខាធិការដ្ឋានថ្នាក់ខេត្ត និងអង្គការសង្គមស៊ីវិល ជួបពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី លើគម្រោងស្តីពី ការជំរុញឲ្យទទួលបានភាពយុត្តិធម៌ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មានអ្នកចូលរួម ២០រូប។
- **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ចាម** បានទទួលជួបពិភាក្សាការងារជាមួយ អង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី ដោយបានលើកយកបញ្ហា របស់ប្រជាពលរដ្ឋចំណាកស្រុក មិនស្របច្បាប់ ការទៅធ្វើការងារជា ពលករតាមរដូវកាល នៅប្រទេសកូរ៉េខាងត្បូង។

**ខ.៣. ទស្សនកិច្ច**

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងថ្នាក់ដឹកនាំមន្ត្រីរបស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ និងក្រុមការងាររបស់អង្គការ UNFPA ចុះទស្សនកិច្ច និងត្រួតពិនិត្យការងារ នៅច្រកទ្វារតំបន់សំខាន់ៗ ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ នៅច្រកទ្វារតំបន់បឹងត្រកួន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ច្រកទ្វារតំបន់អូរបីជាន់ និងច្រកទ្វារអន្តរជាតិប៉ោយប៉ែត។

**គ. ការងារសម្របសម្រួល**

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **១១៩**លើក មានអ្នកចូលរួមសរុប ២.៤៨២នាក់ (ស្រី **៥៧៧**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ៤៣លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៦លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ៧០លើក។(ឧបសម្ព័ន្ធ១)

**IV. ការសន្និដ្ឋានវាយតម្លៃ**

**ក.ចំណុចខ្លាំង**

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ខ. ចំណុចខ្វះខាត ឬភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហួតចប់ការងារ។

- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាព អំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះ ពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំ ប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទង នឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តី សម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែ ស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះ ចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋាន គតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការ ថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការ ប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយ អ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅត្រីមាសទី៣ ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកការកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅ រួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ-ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

# **ឧបសម្ព័ន្ធទី១**

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ១១៨លើក) មនុស្សចំនួន ២.៤៨២នាក់(ស្រី ៥៧៧នាក់)

| **ស្ថាប័ន សម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ជាអធិបតីភាព ក្នុងពិធីបើកសិក្ខាសាលា ស្តីពីការពិនិត្យ សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ដែលរៀបចំឡើងដោយក្រសួងសុខាភិបាល សហការណ៍ជាមួយអង្គការ IOM នៅសណ្ឋាគារសូហ្វីតែលភូគីត្រា។<br>- ជាអធិបតីបើកកិច្ចប្រជុំបច្ចេកទេសស្តីពី ការពិនិត្យរបាយការណ៍វាយតម្លៃដោយស្ម័គ្រចិត្តលើការអនុវត្ត GCM ថ្នាក់ជាតិ ដើម្បីត្រៀមចូលរួមវេទិកាវាយតម្លៃការងារអភិបាលកិច្ចទេសន្តរប្រវេសន៍ជាតិ (IMRF) នៅសណ្ឋាគារភ្នំពេញ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម **កែវ វិសិដ្ឋ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោកជំទាវ **ជូ ពុទ្ធានី** អនុរដ្ឋលេខាធិការក្រសួងផែនការ លោកស្រី **គ្រីស្ទីន ផាកូ** ប្រធានបេសកកម្មអង្គការ IOM ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកក្រសួងយុត្តិធម៌ លោកជំទាវនាយឧត្តមសេនីយ៍ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ ឯកឧត្តម ឧត្តមសេនីយ៍ឯក **អ៊ុក ហៃសីឡា** អគ្គនាយករងអន្តោប្រវេសន៍ លោកជំទាវ ឧត្តមសេនីយ៍ឯក **លឹម រស្មី** អគ្គនាយករងអត្តសញ្ញាណកម្ម ឯកឧត្តម លោកជំទាវ តំណាងក្រសួងសុខាភិបាល តំណាងទីចាត់ការការងារព្រំដែន តំណាងអង្គការ ILO តំណាងអង្គការ UNICEF តំណាងអង្គការ UNW-SAF និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួនទៀត។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តកំពង់ធំ បាត់ដំបង និងខេត្តបន្ទាយមានជ័យ។<br>- បានដឹកនាំនាយនគរបាលជាន់ខ្ពស់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន០២រូប ចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពី "ស្ថិតិទេសន្តរប្រវេសន៍ការងារអន្តរជាតិ" រៀបចំឡើងដោយអង្គការ ILO អន្តរជាតិ សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម **ចី យាង** តំណាងក្រសួងផែនការ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ភ្នំពេញ។<br>- បានចូលរួមសិក្ខាសាលា អំពីសេចក្តីព្រាងសកម្មភាពយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ក្នុងមូលដ្ឋានព្យាបាលនិងថែទាំសុខភាពនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១-២០២៥ នៅខេត្តកំពត ក្រោមអធិបតីភាព ឯកឧត្តម **សៀវ ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល។<br>- ចូលរួមប្រជុំជាមួយក្រុមគ្រូបង្គោល កំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្តីពីការជំរុញឱ្យប្រមូលឯកសារទម្រង់សម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំ គ.ជ.ប.ជ។ |

- ចូលរួមកិច្ចប្រជុំពេញអង្គអាណត្តិទី២ លើកទី១ ឆ្នាំ២០២២ ស្តីពីការអនុម័តសេចក្តីព្រាង ផែនការសកម្មភាពជាតិ គាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០២២-២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច នៅសាលប្រជុំគ្រីស្តាល់ សណ្ឋាគារភ្នំពេញ។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ២៦ច្បាប់ លិខិតចូល ១៧ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២៨ច្បាប់ លិខិតចូល ១៩ច្បាប់។
- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៤០ច្បាប់។
- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន៤១សកម្មភាព។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញ៖
  - ចូលរួមជាគ្រូបង្គោលធ្វើបទឧទ្ទេសនាម ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាល នៅសាលាហ្វឹកហ្វឺន បណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាពពហុជាតិ ស្ថិតក្នុងភូមិទួល ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ជូនសិក្ខាកាមកងកម្ទេចគ្រាប់មិនទាន់ផ្ទុះ។
  - បានដឹកនាំក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ចូលរួមសិក្ខាសាលាស្តីពី «**បិទបញ្ចប់ដំណើរការគម្រោង បញ្ឈប់ការកេងប្រវ័ញ្ចលើកុមារ តាមរយៈការទទួលបានសេវាសមស្រប**» ដែលរៀបចំដោយអង្គការ PLAN International នៅសណ្ឋាគារប៉ារ៉ាដាយ ខេត្តសៀមរាប មានការចូលរួមពីតំណាងក្រុមសហគមន៍ គ្រួសារយុវជន និងកុមារ មកពីខេត្តសៀមរាប និងខេត្តបាត់ដំបង សរុបចំនួន**៥៧**នាក់ ស្រី**៣៦**នាក់។
- លោកឧត្តមសេនីយ៍ទោ **វ៉ន សុភ័ក្រ្តវឌ្ឍនា** ប្រធានក្រុម បានអញ្ជើញចូលរួមជាគ្រូបង្គោលធ្វើបទឧទ្ទេសនាម វគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៣លើក នៅខេត្តត្បូងឃ្មុំ កំពង់ធំ និងខេត្តបាត់ដំបង មានអ្នកចូលរួមសរុប ៦០រូប។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ៖
  - បានអញ្ជើញចូលរួមប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិភាក្សាពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប។
  - បានធ្វើបទសម្ភាសន៍ជាមួយអង្គការ IOM សម្រាប់ការស្រាវជ្រាវអំពីប្រសិទ្ធភាពនៃកម្មវិធី ជំនួយក្នុងការវិលត្រឡប់មកវិញ និងសមាហរណកម្ម នៅប្រទេសកម្ពុជា ជាពិសេសទៅលើពលករក្នុងខេត្តបាតដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប។
- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុម បានចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតសញ្ញាណ នៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- ឧត្តមសេនីយ៍ទោ **កែវ ផល្លា** ប្រធានក្រុម បានចូលរួមជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីជួរមុខមកពីស្រុកនានានៃខេត្តចំនួន០៦ មាន ដូចជា៖ ខេត្តកោះកុង សៀមរាប បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ និងឧត្តរមានជ័យ ស្តីពី «កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយ អំពើជួញដូរមនុស្ស និងការរំលោភបំពាន» ដឹកនាំដោយលោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង និងជាប្រធានក្រុមគ្រូបង្គោលនៃអគ្គ លេខាធិការដ្ឋានគ.ជ.ប.ជ ក្រោមជំនួយឧបត្ថម្ភដោយអង្គការមូលនិធិអប់រំកុមារ នៃអង្គការសហប្រជាជាតិ (UNICEF)។
- បានចូលរួមប្រជុំជាមួយក្រុមគ្រូបង្គោល កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការដឹកនាំ សម្របសម្រួលដោយ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ស្តីពីការជំរុញ ឱ្យប្រមូលឯកសារទម្រង់សម្ភាសន៍ « កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើ ជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំ គ.ជ.ប.ជ។
- បានចូលរួមកិច្ចប្រជុំជាមួយអង្គភាពពាក់ព័ន្ធ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង។

▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**

- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ និងជាសមាជិកអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងារ របស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុម ប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ(អ.អ.ផ)៖
  - ○ បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៣ នៃអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងារ របស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេស អាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.អ.ផ នៅ សណ្ឋាគារស៊ើដង់សុខាភ្នំពេញ គឺដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ជុំទី៩ របស់កម្ពុជា ដើម្បីដាក់ជូនមហាសន្និបាតរបស់ក្រុមការងារ ហិរញ្ញវត្ថុ (FATF)។
  - ○ បានចូលរួមកិច្ចប្រជុំបច្ចេកទេស ដើម្បីបន្តពិនិត្យខ្លឹមសារ ស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ (SOP) រវាងកម្ពុជា-ថៃ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅភោជនីយដ្ឋានទន្លេបាសាក់២។
  - ○ បានចូលរួមសន្និសីទភាពជាដៃគូរបស់ ASEAN Commission on the Promotion and Protection of the rights of Women and Children (ACWC) លើកទី៣ ក្រោមប្រធានបទ "Towards A Cohesive and Responsive Future "តាមប្រព័ន្ធវីដេអូរ ZOOM ក្រោមការដឹកនាំដោយ ឯកឧត្តម អគ្គលេខាធិការអាស៊ានទទួលបន្ទុកសហគមន៍សង្គម-វប្បធម៌អាស៊ាន ដោយមានការអញ្ជើញចូលរួមពី លោកជំទាវប្រធានACWCកម្ពុជា ព្រមទាំងអ្នកពាក់ ព័ន្ធជាតិ និងអន្តរជាតិ ប្រមាណជា១០០នាក់។

| | |
|---|---|
| | ○ បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៤ នៃអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.អ.ផ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។<br>○ បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីលទ្ធផលការងារ និងទិសដៅការងារពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខាភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ<br>○ បានអញ្ជើញចូលរួមកិច្ចប្រជុំ ចែករំលែកគុការហ្វេះ ការបង្កើតកន្លែងធ្វើការប្រកបដោយសុវត្ថិភាព និងមានការគោរពនៅក្នុងឧស្សាហកម្មកាត់ដេរ នៅសណ្ឋាគារពូលូវ៉េ។ កម្មវិធីនេះមានគោលបំណងដើម្បីចែករំលែកចំណេះដឹងបទពិសោធន៍ និងការអនុវត្តល្អទាក់ទងនឹងការទប់ស្កាត់ ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ក្រោមការឧបត្ថម្ភថវិកាពី រដ្ឋាភិបាលអូស្ត្រាលី ដោយមានតំណាងមកពីក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិល សរុបចំនួន៣០នាក់ ស្រី១៨នាក់។<br>○ បានអញ្ជើញចូលរួមក្នុងវេទិកាពិភាក្សាលើការអនុវត្ត អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារនៅកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ។<br>○ បានចូលរួមប្រជុំជាមួយក្រុមគ្រូបង្គោល កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ស្តីពីការជំរុញ ឱ្យប្រមូលឯកសារទម្រង់សម្ភាសន៍ « កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំ គ.ជ.ប.ជ។<br>- លោកឧត្តមសេនីយ៍ត្រី ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានចូលរួមសិក្ខាសាលា ស្តីពីការអនុវត្តរបស់កម្ពុជា លើផែនការ សកម្មភាពមហាអនុតំបន់មេគង្គខមមីតទី៤ ( SPA IV) និងការពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី១ លើការ រៀបចំយន្តការបញ្ជូនឆ្លងដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួង កិច្ចការនារី នៅសណ្ឋាគារកាំបូឌីយ៉ាណា សរុបមានចំនួន **៧៦**នាក់ ស្រី៤០នាក់។<br>- លោកស្រី អនុប្រធានក្រុម បានចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីស្តីពីការអង្កេតសញ្ញាណ នៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ នៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- បានអមដំណើរ លោកជំទាវ អគ្គលេខាធិការ គជ.ប.ជ. បើកវគ្គបណ្តុះបណ្តាលស្តីពីការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមការឧបត្ថម្ភរបស់អង្គការ IOM នៅខេត្តត្បូងឃ្មុំ និងខេត្តបាត់ដំបង។ |

| | |
|---|---|
| | - បានអមដំណើរ លោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ បិទវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ នៅខេត្តសៀមរាប។<br>- បានចូលរួមសិក្ខាសាលា ស្តីពីការអនុវត្តរបស់កម្ពុជា លើផែនការ សកម្មភាពមហាអនុតំបន់មេគង្គខមមីតទី៤ ( SPA IV) និងការពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី១ លើការ រៀបចំយន្តការបញ្ជូនឆ្លងដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួង កិច្ចការនារី នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិត្រីភាគី ស្តីពីការរៀបចំផែនការសម្រាប់អនុវត្តឯកច្ឆ័នភាពអាស៊ាន ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **ហូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារភ្នំពេញ។<br>- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសដើម្បីពិនិត្យ និងផ្តល់យោបល់លើ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ នៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីឆ្ពោះទៅមុខដើម្បីលើកកម្ពស់ ការជ្រើសរើសប្រកបដោយក្រមសីលធម៌ រៀចំដោយអង្គការសង់ត្រាល់ នៅសណ្ឋាគារអូឡាំព្យាស៊ីធី។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន០២លើក។<br>- បានចូលរួមប្រជុំជាមួយអង្គភាពចំណុះក្រសួងសង្គមកិច្ច អតីតីយុទ្ធជន និងយុវនីតិសម្បទាចំនួ០១លើក។<br>- បានចាត់មន្ត្រីចូលរួមជាគ្រូបង្គោលនៅក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតសញ្ញាណ នៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅខេត្តបន្ទាយមានជ័យ ចំនួន០១លើក។<br>- បានចាត់មន្ត្រីចូលរួមសិក្ខាសាលា ស្តីពីការអនុវត្តរបស់កម្ពុជាលើផែនការសកម្មភាពមហាអនុតំបន់មេគង្គខមមីតលើកទី៤ និងការពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី១ លើកការរៀបចំយន្តការបញ្ជូនឆ្លងដែន រៀបចំដោយក្រសួងកិច្ចការនារី និងអង្គការ UNDP។<br>- បានចាត់មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល គ្រូបង្គោលលើការគ្រប់គ្រងករណីក្នុងការវិលត្រឡប់ និងការធ្វើសមាហរណកម្ម នៅខេត្តសៀមរាប។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៧០លើក អ្នកចូលរួមសរុបចំនួន ២.១៩៧នាក់(ស្រី ៤៨៣នាក់)** | |
| ខេត្តកណ្តាល | - លោកជំទាវ ហ៊ុន កុសនី អភិបាលរង និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បាន៖ ១.ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែ ០២លើក អ្នកចូលរួម ៥៣នាក់ ស្រី៣៨នាក់។ ២.ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តគម្រោងកិច្ចការពារកុមារ និងការគ្រប់គ្រងថវិកា នៅសាលាខេត្តកំពត។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន១១លើក អ្នកចូលរួម ៣១៩នាក់ ស្រី១៦៥នាក់។ |

| | |
|---|---|
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំប្រចាំខែ ០១លើក មានអ្នកចូលរួម **៥២**នាក់ ស្រី**២៦**នាក់។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង ស្រុក បានរៀបចំកិច្ចប្រជុំ ០៩លើក អ្នកចូលរួម **៣៣៦**នាក់ ស្រី**៩២**នាក់។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួម៖ ១.កម្មវិធីបិទវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពាន និងក្រមសីលធម៌មន្ត្រីនៅទីតាំងធ្វើចត្តាឡីស័ក ដល់មន្ត្រីពាក់ព័ន្ធក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ០១លើក ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។ ២.កិច្ចប្រជុំបូកសរុបលទ្ធផលនៃការបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន និងក្រមសីលធម៌មន្ត្រីនៅទីតាំងធ្វើចត្តាឡីស័ក ០១លើក។ ៤.ដឹកនាំកិច្ចប្រជុំគម្រោងកិច្ចការពារកុមារ ០១លើក អ្នកចូលរួមចំនួន២២នាក់ ស្រី១០នាក់។<br>- ក្រុមការងារជំនួយការលេខាធិការដ្ឋាន បានចូលរួមសម្របសម្រួលលើការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន និងក្រមសីលធម៌មន្ត្រីនៅទីតាំងធ្វើចត្តាឡីស័ក ០១លើក នៅសាលាខេត្ត រៀបចំដោយ គ.ជ.ប.ជ។ |
| ខេត្តត្បូងឃ្មុំ | - លោកជំទាវ **នី ចាន់ធីតា** ប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានអញ្ជើញចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី ការប៉ះទង្គិចផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមជ្ឈមណ្ឌលអាស៊ូណា ខេត្តត្បូងឃ្មុំ ដែលរៀបចំដោយអង្គការ IOM ក្រោមអធិបតីភាព លោកជំទាវឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ មានអ្នកចូលរួម **២៣**នាក់ ។ |
| ខេត្តឧត្តរមានជ័យ | - ចូលរួមវគ្គបណ្តុះបណ្តាលគោលការណ៍ណែនាំស្តីពី កិច្ចការពារផ្លូវច្បាប់សិទ្ធិស្ត្រីនិងកុមារ ក្នុងគោលបំណងអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការជួយជនរងគ្រោះទាន់ពេលវេលា ព្រមទាំងបំពេញភារកិច្ចរបស់ខ្លួនឲ្យកាន់តែប្រសើរឡើង ០១លើក។<br>- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ច្បាប់និងឯកសារក្បួននីតិវិធីប្រតិបត្តិការ របស់មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ ០១លើកអ្នកចូលរួម ៤៥នាក់។<br>- កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារចំនួន ០១លើក អ្នកចូលរួមចំនួន១៥នាក់ ស្រី១០នាក់។ |
| ខេត្តកំពង់ឆ្នាំង | - លោកជំទាវប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំប្រចាំខែ ០២លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្សអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលមានមន្ត្រីនគបាលជំនាញប្រឆាំងការជួញដូរមនុស្ស អ្នកចូលរួម០៦នាក់ ស្រី០៤នាក់។ |
| ខេត្តតាកែវ | - ថ្ងៃទី០៧/០៨ ខែឧសភា ឆ្នាំ២០២២ លោកស្រីគា សុភូ អភិបាលរងខេត្តនិងជាអនុប្រធានអចិន្ត្រៃយ៍ បានចូលរួមប្រជុំ និងចុះតាមខ្នងផ្ទះ ចំនួន០៦លើក បានបញ្ជ្រាបដល់ប្រជាពលរដ្ឋធ្វើយ៉ាងណាអោយគេចផុតពីអំពើជួញដូរមនុស្ស និងអំពើហិង្សាដល់គ្រួសារ ពិសេសស្ត្រីនិងកុមារ អ្នកចូលរួមសរុបចំនួន **៥៥០**នាក់។ |
| ខេត្តព្រៃវែង | - ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត បានចូលរួមជាអធិបតីក្នុងកិច្ចប្រជុំក្រុមការងារកិច្ចការពារកុមារខេត្ត ដើម្បីពិនិត្យលើវឌ្ឍនភាព នៃការអនុវត្តផែនការកិច្ចការពារកុមារឆ្នាំ២០២១-២០២២ និងរៀបចំផែនការកិច្ចការពារកុមាររយៈពេល៣ឆ្នាំ (២០២៣-២០២៥) អ្នកចូលរួមចំនួន៥០នាក់។<br>- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចូលរួមសម្របសម្រួលក្នុងសិក្ខាសាលា ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស ដែលរៀបចំដោយអង្គការហាកា នៅស្រុកកំពង់ត្របែក និងស្រុកព្រះស្តេច សរុបចំនួន៦០នាក់។<br>- លេខាធិការដ្ឋានបានរៀបចំកិច្ចប្រជុំដើម្បីរៀបចំផែនការសកម្មភាពកិច្ចការពារកុមារឆ្នាំ២០២៣-២០២៥ ០២លើក អ្នកចូលរួម ៨៦នាក់ ស្រី៤៤នាក់។ |

| | |
|---|---|
| | - ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត ប្រធានគណៈបញ្ជាការឯកភាពខេត្ត និងជាប្រធានគ ជ.ប.ខ.បានណែនាំដល់ក្រុង ស្រុក ឱ្យផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងករណីពពោះជំនួស ដើម្បីជៀសផុតពីការជួញដូរមនុស្ស និងល្បិចកលរបស់ជនឆ្លៀតឱកាសមួយចំនួន នៅក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ០២លើក ក្រោមអធិបតីភាព មានអ្នកចូលរួមសរុប **១៥៨**នាក់។ |
| **ខេត្តក្រចេះ** | - មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ បានរៀបចំកិច្ចប្រជុំប្រចាំខែ ០១លើក និងបានណែនាំផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស វិធីទប់ស្កាត់ និងការរំលោភបំពានផ្លូវភេទតាមគ្រប់រូបភាពដល់មន្ត្រីគ្រប់ជាន់ថ្នាក់បានដឹង និងណែនាំមន្ត្រីគ្រប់ៗ គ្នាដើម្បី ជួយផ្សព្វផ្សាយបន្តនៅតាមសហគមន៍ ឬភូមិ ឃុំ ដែលបានចុះការងារដល់ឲ្យដឹងបញ្ហាផ្សេងៗជៀសលវាងចាញ់ បោកជនខិលខូច និងជនឆបោកមួយចំនួន។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយសហគ្រាសគ្រឹះស្ថានក្នុងខេត្តចំនួន ០៣លើក សរុប **១១៣**នាក់ស្រី**៣៥**នាក់។<br>- មន្ត្រីលេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតនៃសញ្ញាណការប៉ះទង្គិចផ្លូវចិត្តរបស់ជនរងគ្រោះដោយអំពើជួយដូរមនុស្ស នៅសណ្ឋាគារគ្លរៀសនិងស្ប៉ា នៅខេត្តកំពង់ធំ ០១លើក។ |
| **ខេត្តបាត់ដំបង** | - ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បច្ចេកវិទ្យា និងបទពិសោធន៍ចំពោះការរំលោភបំពានតាមប្រព័ន្ធបច្ចេកវិទ្យាចំពោះកុមារនិងយុវជន រៀបចំដោយអង្គការធាលហ្វាន ០១លើក មានអ្នកចូលរួម**២២**នាក់ ស្រី**១៣**នាក់។<br>- ចូលរួមប្រជុំស្តីពី សុវត្ថិភាពទេសន្តប្រវេសន៍នៅកម្ពុជា នៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ០១លើក មានអ្នកចូលរួម**២៥**នាក់ ស្រី**០៧**នាក់។<br>- ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអង្គការ ILO ស្តីពីការអនុវត្តសម្រាប់គម្រោងទេសន្តប្រវេសន៍ តាមប្រព័ន្ធអនឡាញ ០១លើក។<br>- ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចការងារស្តីពី នីតិវិធីនៃការចុះយុទ្ធនាការផ្សព្វផ្សាយការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្ម នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលរំលឹក ស្តីពីការយល់ដឹងមូលដ្ឋាននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកិច្ចការពារកុមារជូនដល់បុគ្គលិកសង្គម និងមន្ត្រីជួរមុខក្នុងសហគមន៍ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "គោលការណ៍ណែនាំថ្នាក់ជាតិអំពីការការពារកុមារ" ក្នុងគោលបំណងលើកកម្ពស់សិទ្ធិកុមារ និងរក្សាសុវត្ថិភាពកុមារ។<br>- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "**វិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដារអេប្បូរមាSOP តាមគន្លងប្រក្រតីភាពថ្មីសម្រាប់អាជីវកម្មភោជនីយដ្ឋានអាហារដ្ឋានទេសចរណ៍**" នៅសាលាខេត្តបាត់ដំបង។ |
| **ខេត្តបន្ទាយមានជ័យ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០១លើក។<br>- លោកស្រីឧត្តមសេនីយ៍ស្នងការរង និង មន្ត្រីប្រឆាំងការជួញដូរមនុស្ស ចំនួន **១៣**រូប បានចូលរួមវគ្គបណ្តុះបណ្តាលបន្តស្តីពី ការអង្កេតនៃសញ្ញាណការប៉ះទង្គិចផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តបន្ទាយមានជ័យ ០១លើក។ |

| | |
|---|---|
| | - លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានចូលរួម៖ **១**.សិក្ខាសាលាស្តីពី ប្រព័ន្ធការពារកុមារដែលមានហានិភ័យនៃអំពើហិង្សាកុមារនៅតាមផ្លូវ ជនរងគ្រោះនៃការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ការជួញដូរកម្លាំងពលកម្មកុមារដែលបំបែកចេញពីគ្រួសារ ០១លើក។ ២.ប្រជុំពិភាក្សា និងធ្វើបទបង្ហាញសាកល្បងលើប្រព័ន្ធត្រួតពិនិត្យទិន្នន័យលំហូររបស់ពលករ តាមប្រព័ន្ធអនឡាញ ០១លើក។ **៣**.សហការជាមួយមន្ត្រីសង្គមកិច្ចក្រុង និងអាជ្ញាធរនៅក្នុងក្រុងប៉ោយប៉ែត ចុះចែកស្បៀងសង្គ្រោះបន្ទាន់ ជូនដល់គ្រួសារកុមារក្រីក្ររងគ្រោះ និងងាយរងគ្រោះ ក្នុងសហគមន៍ចំនួន ២១គ្រួសារ មានកុមារ **៥១**នាក់ កុមារី**១៩**នាក់ ដែលទទួលរងផលប៉ះពាល់ពីការធ្វើចំណាកស្រុក។<br>- ក្រុមអភិវឌ្ឍយុវជនស្ម័គ្រចិត្ត បានទទួលការបណ្តុះបណ្តាលកសាងសមត្ថភាពបង្កើនចំណេះដឹងស្តីពី សុវត្ថិភាពនៃការធ្វើចំណាកស្រុក ដើម្បីយកទៅផ្សព្វផ្សាយអប់រំដល់ប្រជាពលពលរដ្ឋ ពលករតាមមូលដ្ឋាន ០១លើក។<br>- ការិយាល័យការងារសង្គ្រោះ សហការជាមួយមន្ត្រីប៉ូលីសទៅសម្ភាសន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ០៤នាក់ នៅភូមិប្រជាធម្មលិច សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត។<br>- លោកស្រី **រស់ សុផានី** បានអញ្ជើញចូលរួមបើកវគ្គបណ្តុះបណ្តាល ស្តីពី «ការអង្កេតនៃសញ្ញាប៉ះទង្គិចផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស»។<br>- តំណាង គ.ខ.ប.ជ ចំនួន០២នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ និងការកំណត់អសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពាន ក្រមសីលធម៌មន្ត្រីនៅទីតាំងធ្វើចត្តាឡីស័ក នៅសាលាខេត្តសៀមរាប ០១លើក។ |
| **ខេត្តកំពត** | - បានរៀបចំកិច្ចប្រជុំលេខាធិការដ្ឋាន ០២លើក ផ្សព្វផ្សាយលិខិតបទដ្ឋានថ្មីៗពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួម ៤៣នាក់ ស្រី២០នាក់។ |